# របាយការណ៍ប្រចាំត្រីមាសទី៣
# ឆ្នាំ ២០២៣

០១ កក្កដា - ៣០ កញ្ញា ២០២៣

## អរ អិម អេ (ខេមបូឌា) ម.ក

R M A (CAMBODIA) PLC.



ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក
ទីស្នាក់ការចុះបញ្ជីផ្ទះលេខ ២៧ ផ្លូវលេខ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទទំនាក់ទំនង: +៨៥៥ (0) ២៣-៨៨៨-000, ទូរស័ព្ទចល័ត: +៨៥៥ (0) ២៣-៩២៦-៧៥២
www.cambodia.rmagroup.net

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ត្រីមាសទី៣ ឆ្នាំ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ១.០៦៦.៥៤៨.៨០២ | ៨៨៩.២៩៥.២៣២ | ៦០៨.១៥៩.៥៣០ |
| បំណុលសរុប | ៥៣១.៧២៩.៦២៣ | ៤៥១.៣៩២.៤៣៣ | ៣២២.២៤០.៨២០ |
| មូលធនក្រុមហ៊ុនសរុប | ៥៣៤.៨១៩.១៧៩ | ៤៣៧.៩០២.៧៩៩ | ២៨៥.៩១៨.៧១០ |

| ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល) | ត្រីមាសទី ៣ ឆ្នាំ២០២៣ | ត្រីមាសទី ៣ ឆ្នាំ២០២២ | ត្រីមាសទី ៣ ឆ្នាំ២០២១ |
|---|---|---|---|
| ចំណូលសរុប | ៣៦៦.៦៥៧.៧១០ | ៧៨៥.៦៩៣.៨៩១ | ៤៦៩.៩១០.៣៨៤ |
| ប្រាក់ចំណេញ/(ខាត) មុនបង់ពន្ធ | ១៥.៩៥៥.៣៤៦ | ១២១.៥៨៩.៤៨២ | ៥៣.៦៤៥.៥៦៨ |
| ប្រាក់ចំណេញ (ខាត) ក្រោយបង់ពន្ធ | ១៣.២៤៣.៥១៩ | ៩៨.៤៣៦.៩៧៩ | ៤៤.៤៥១.៤២៧ |
| លទ្ធផលចំណេញលម្អិតក្នុងគ្រា | ១០.៥៩៧.៣៧៦ | ១០១.០៩០.៦១៨ | ៤៤.៥៥៥.២៤៨ |

| អនុបាតហិរញ្ញវត្ថុ | ត្រីមាសទី ៣ ឆ្នាំ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| អនុបាតសាធនភាព | ១,០ | ១,០ | ១,១ |
| អនុបាតចរន្ត (Current Ratio) | ២,០ | ២,០ | ២,០ |
| អនុបាតចរន្តលឿន (Quick Ratio) | ០,៤ | ០,៧ | ១,០ |

| អនុបាតចំណេញភាព | ត្រីមាសទី ៣ ឆ្នាំ២០២៣ | ត្រីមាសទី ៣ ឆ្នាំ២០២២ | ត្រីមាសទី ៣ ឆ្នាំ២០២១ |
|---|---|---|---|
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ១,១% | ១៤,៦% | ១០,៣% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ២,២% | ២៩,៥% | ១៩,០% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៦,០% | ១៩,២% | ១៥,៤% |
| គម្លាតចំណេញ (Profit Margin) | ២,៩% | ១២,៩% | ៩,៥% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | ២,៨ | ៣៦,០ | ២៧,៤ |

# ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសខ្មែប










ប្រាក់ចំណូល និង ចំណូលសុទ្ធ (គិតជាពាន់រៀល)
2,500,000,000
2,000,000,000
1,500,000,000
1,000,000,000
500,000,000
-
12.0%
11.0%
10.0%
9.0%
8.0%
7.0%
6.0%
១.៦២៦.៥៤០.០២៤
៩,៨%
២.២០៣.២៥៣.៤៥៣
១១,២%
១.៤៨៤.៧១៦.០៣៨
៨,៥%
២០២១
២០២២
ខែមករា-ខែកញ្ញា, ឆ្នាំ២០២៣
ប្រាក់ចំណូល
ចំណូលសុទ្ធ%

## សមាជិកក្រុមប្រឹក្សាភិបាល



លោក Wiedmann Christian | លោក ខន សាំង | លោក Kevin Whitcraft | លោក Tom Whitcraft | លោក Ith Vichit

លោក Kevin Whitcraft

ប្រធានក្រុមប្រឹក្សាភិបាល

លោក ខន សាំង

អភិបាលប្រតិបត្តិ

លោក Tom Whitcraft

អភិបាលមិនប្រតិបត្តិ

លោក Wiedmann Christian

អភិបាលមិនប្រតិបត្តិ

លោក Ith Vichit

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក (តទៅនេះហៅកាត់ថា "ក្រុមហ៊ុន RMAC") ស្របទៅតាមលក្ខខណ្ឌតម្រូវរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

សេដ្ឋកិច្ចពិភពលោកមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់នៅឆ្នាំ ២០២៣ រួមជាមួយនឹងការព្យាករណ៍កំណើនរបស់ធនាគារពិភពលោកត្រឹមតែ ៣,២% ប៉ុណ្ណោះ។ ស្ថានភាពនេះនឹងធ្វើឲ្យមានផលប៉ះពាល់ទៅដល់ការនាំចេញរបស់ប្រទេសកម្ពុជា ដែលជាចំណែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចជាតិ។ អត្រាកំណើនផលិតផលក្នុងស្រុកសរុប (GDP) របស់កម្ពុជាមានការធ្លាក់ចុះត្រឹម +៥,០%។ អនុបាតអានុភាពនៃវិស័យហិរញ្ញវត្ថុមានការកើនឡើងយ៉ាងខ្លាំង ភ្ជាប់ជាមួយនឹងអត្រាឥណទាននៃផលិតផលក្នុងស្រុកសរុបលើស ១០០% ដែលធ្វើឲ្យវិស័យហិរញ្ញវត្ថុងាយទទួលរងគ្រោះនូវវិបត្តិមួយចំនួនដូចជាការកើនឡើងនៃអត្រាការប្រាក់, សម្ពាធថវិកាគ្រួសារ ព្រមទាំងអាជីវកម្ម។

ដោយយោងតាមការវិភាគរបស់យើងបានបង្ហាញថាវិស័យយានយន្តនៅកម្ពុជាកំពុងប្រឈមនឹងការធ្លាក់ចុះគួឲ្យកត់សម្គាល់នៅឆ្នាំ២០២៣, ជាមួយនឹងការធ្លាក់ចុះនៃការលក់ប្រមាណជា -៣០% ប្រៀបជាមួយនឹងអំឡុងពេលដដែលនេះផងដែរនាឆ្នាំ២០២២។ ការធ្លាក់ចុះយ៉ាងខ្លាំងនេះ គឺដោយសារកត្តាមួយចំនួន រួមបញ្ចូលទាំង ផលប៉ះពាល់ក្រោយការរាតត្បាតនៃជម្ងឺកូវីដ ១៩, ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក, ការកើនឡើងនៃអតិផរណា និងហានិភ័យហិរញ្ញវត្ថុ។

នៅក្នុងកំឡុងត្រីមាសទី៣ នៃឆ្នាំ២០២៣ RMAC ប្រឈមជាមួយការធ្លាក់ចុះនៃការលក់ -៥៦% បើធៀបទៅនឹងកំឡុងពេលត្រីមាសដូចគ្នានាឆ្នាំ២០២២។ ប្រាក់ចំណេញសុទ្ធនៃត្រីមាសនេះត្រូវបានធ្លាក់ចុះប្រមាណ -៨៦%។ ទោះបីជាយ៉ាងណាក៏ដោយ ពីមួយឆ្នាំទៅមួយឆ្នាំ RMAC នៅតែរក្សាការនាំមុខទីផ្សារយានយន្តមិនប្រណិត ជាមួយនឹងម៉ាក Ford និង Changan។ ផ្អែកលើមូលដ្ឋានពីមួយឆ្នាំទៅមួយឆ្នាំ ប្រាក់ចំណូលគឺធ្លាក់ចុះប្រមាណ -៤% ធៀបនឹងកំឡុងពេលដដែលនាឆ្នាំ២០២២ ប៉ុន្តែ RMAC នៅតែរក្សាតារាងតុល្យភាពដ៏រឹងមាំ។

RMAC នឹងបន្តខិតខំប្រឹងប្រែងចែកចាយផលិតផលដែលមានតម្រូវការខ្ពស់ ក៏ដូចជាផ្តល់នូវសេវាដែលគ្មានគូប្រៀបទៅកាន់អតិថិជនប្រចាំរបស់ខ្លួន។ ក្រុមហ៊ុនយើងក៏កំពុងធ្វើការវិនិយោគទៅលើបណ្តាញនៃអគារតាំងបង្ហាញរថយន្ត និងសេវាកម្មក្រោយការលក់ ដោយបញ្ចូលទៅក្នុងអគារតែមួយ ដែលអគារនេះទើបបើកសម្ពោធថ្មីនៅខណ្ឌជ្រោយចង្វារ។ ការធ្វើបែបនេះ គឺជាការបង្ហាញពីភាពប្តេជ្ញាចិត្តរយៈពេលវែងរបស់យើងទៅកាន់ប្រជាជានកម្ពុជា។ មិនត្រឹមតែប៉ុណ្ណោះ RMAC ផ្តល់ជាជំនួយគាំទ្រទៅដល់ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការផ្សព្វផ្សាយលក្ខណៈពិសេសរបស់ RMAC ទៅកាន់សិស្សនិស្សិតនៅក្នុងកម្មវិធីពិព័ណ៌ការងារធំៗ។

ជាចុងបញ្ចប់ យើងមានមោទនភាពយ៉ាងខ្លាំង ដោយសារតែក្រោយការបើកសម្ពោធត្រឹមរយៈពេលមួយឆ្នាំប៉ុណ្ណោះ រោងចក្រដំឡើងរថយន្តរបស់យើងនៅខេត្តពោធិ៍សាត់មានការរីកចម្រើនគួរឲ្យកត់សម្គាល់។ ក្នុងឱកាសនេះដែរ RMAC បានឧបត្ថម្ភរថយន្តសង្គ្រោះបន្ទាន់ម៉ាក Ford Ranger ចំនួនពីរគ្រឿង ទៅកាន់កាកបាទក្រហមកម្ពុជា។

ខ្ញុំបាទតំណាងឲ្យក្រុមប្រឹក្សាភិបាល សូមថ្លែងអំណរគុណចំពោះអតិថិជនដែលមានភក្តីភាពដែលបានគាំទ្រដល់ក្រុមហ៊ុនយើងក្នុងគ្រាលំបាកក្នុងព្រះរាជាណាចក្រកម្ពុជាកន្លងមក ហើយយើងក៏សូមជូនពរឲ្យប្រជាជនកម្ពុជាទាំងអស់មានសុវត្ថិភាព និងសុខភាពល្អគ្រប់ៗគ្នា។

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល

## មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ 3

ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប ........ 5

សមាជិកក្រុមប្រឹក្សាភិបាល ........ 7

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ 8

ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ........ 11

ក .ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ ........ 11

ខ .សកម្មភាពអាជីវកម្ម ........ 11

គ .ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស ........ 12

ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ 14

ក .លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក ........ 14

ខ .រចនាសម្ព័ន្ធប្រាក់ចំណូល ........ 14

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ ........ 15

ផ្នែកទី៤ .ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង ........ 16

ក .ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ 16

ខ .កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ ........ 17

គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល ........ 17

ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ ........ 17

ង. ផលប៉ះពាល់នៃអតិផរណា ........ 17

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ........ 18

ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ ........ 18

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ........ 19

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ | អ អិម អេ (ខេមបូឌា) ម.ក |
|---|---|
| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង | RMA (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH2000121A44 |
| អាសយដ្ឋាន | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (0) ២៣ ៨៨៣ ៨៨៨ / ១២ ៨៦៧ ៦៩៧ |
| លេខទូរសារ | +៨៥៥ (0) ២៣ ៤២៦ ៧៥២ |
| គេហទំព័រ | www.cambodia.rmagroup.net |
| អ៊ីម៉ែល | saing.ngorn@rmagroup.net |
| លេខចុះបញ្ជីក្រុមហ៊ុន | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦៨/២០ គ.ម.ក សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ | លោក ងន សាំង |
| លេខាធិការក្រុមហ៊ុន | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត កសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, Jaguar Land Rover, Changan, After-Sales of Mercedes-Benz, John Deere, TCM, JCB, FUSO, Changan និង Piaggio។ ថ្មីៗនេះ RMAC បានដាក់ឱ្យដំណើរការនូវផ្នែកថ្មីមួយដែលមានឈ្មោះថា គ្រឿងបន្លាប់រថយន្ត (Automobile Acccessories) ក្នុងគោលបំណងលក់ថ្នាំលាបរថយន្តដែលមានគុណភាពខ្ពស់សម្រាប់ការងារផ្នែកជួសជុលតួរឡាន ក្រោមម៉ាក R-M (ជាផ្នែកមួយនៃក្រុមហ៊ុន BASF Group) និងអាគុយរថយន្ត ក្រោមម៉ាកយីហោក្វរ៉េ RG Batteries ។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងសេវាថែទាំក្រោយការលក់។

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស

ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសត្រូវបានកំណត់ដូចខាងក្រោម៖

### ខែកក្កដា ឆ្នាំ ២០២៣

**គម្រប់ខួប ១ឆ្នាំនៃរោងចក្រដំឡើងរថយន្ត ម៉ាក** FORD.

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ត្រូវជាមួយនឹងថ្ងៃគម្រប់ខួបលើកទីមួយ នៃការសម្ពោធរោងចក្រ Ford Assembly Plant នេះ ក្រុមហ៊ុន អ អិម អេ ខេមបូឌា បានរៀបចំប្រគល់រថយន្តសង្គ្រោះបន្ទាន់ចំនួន ២ គ្រឿង ដល់កាកបាទក្រហមកម្ពុជា ដោយបានអញ្ជើញសារព័ត៌មានសាខាខេត្តពោធិ៍សាត់ ចូលរួមក្នុងពិធីនេះដែលធ្វើឡើងនៅ MB state-of-the - art facilities ស្ថិតនៅលើផ្លូវមហាវិថី ហ៊ុន សែន។



### ខែកក្កដា ឆ្នាំ ២០២៣

**ការបរិច្ចាគ**

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ក្រុមហ៊ុន អ អិម អេ ខេមបូឌា បានរៀបចំពីធីប្រគល់រថយន្តសង្គ្រោះបន្ទាន់ចំនួន២គ្រឿង ដល់កាកបាទក្រហមកម្ពុជា។



## ខែកក្កដា ឆ្នាំ ២០២៣

### ទិសដៅអាជីព

នៅថ្ងៃទី ១៨ ខែកក្កដា ថ្មីៗនេះ ក្រុមហ៊ុន អ អិម អេ ខេមបូឌា បានសហការជាមួយសាកលវិទ្យាល័យ ន័រតុន (Norton University) រៀបចំសិក្ខាសាលាតម្រង់ទិសអាជីព ដោយមានចំណងជើងថា "ការតម្រង់ទិសអាជីព"។ សិក្ខាសាលានេះ ធ្វើឡើងដោយមានវត្តមានរបស់វាគ្មិនកិត្តិយសគឺៈ លោក Grant Honeymen ដែលជាប្រធានគ្រប់គ្រងទូទៅផ្នែកធនធានមនុស្ស និង រដ្ឋបាល និងលោក សុខ សុន្ទារ៉ា ជាប្រធានគ្រប់គ្រងទូទៅនៃ ត្រាក់ទ័រ ចនឌារ ខេមបូឌា នៅក្រុមហ៊ុន អ អិម អេ ខេមបូឌា។




## ខែសីហា ឆ្នាំ ២០២៣

### ការបើកសម្ពោធអគារតាំងបង្ហាញរថយន្តម៉ាក FORD CHROY CHANGVAR

ពិធីនេះ ត្រូវបានអញ្ជើញចូលរួមពីថ្នាក់ដឹកនាំនៃក្រុមហ៊ុន Ford Motor Company ក្រុមហ៊ុន RMA Group ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) និងភ្ញៀវកិត្តិយសចំនួន ១០០ នាក់។



## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក. លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក

នៅកំឡុងត្រីមាសទី៣ នៃឆ្នាំ២០២៣ គឺជាកំឡុងពេលដែលពោរពេញទៅដោយបញ្ហាប្រឈមយ៉ាងច្រើននៅក្នុងវិស័យយានយន្តនៅកម្ពុជា ដែលបានធ្លាក់ចុះ -៤៥% ធៀបទៅនឹងត្រីមាសទី៣ នៃឆ្នាំ២០២២។

នៅក្នុងបរិបទលំបាកបែបនេះ, RMAC ទទួលបានសមិទ្ធិផលសំខាន់ៗនៅចុងត្រីមាសទី៣ នៃឆ្នាំ២០២៣ រួមមាន៖

**ភាពឈានមុខគេក្នុងទីផ្សាររបស់រថយន្តម៉ាក Ford៖**

រថយន្តម៉ាក Ford នៅតែរក្សាចំណាត់ថ្នាក់លេខមួយនៃរថយន្តដែលលក់ដាច់បំផុតនៅលើទីផ្សារនៃប្រទេសកម្ពុជា ក្នុងចំណោមទីផ្សាររថយន្តដែលមិនប្រណិត ជាមួយនឹងរថយន្តម៉ាក Ford Ranger ត្រូវបានជាប់ចំណាត់ថ្នាក់លេខមួយនៅក្នុងផ្នែករថយន្ត Pick-up ក្នុងប្រទេសកម្ពុជានៅពាក់កណ្តាលត្រីមាសទី១ ឆ្នាំ២០២៣។

**គ្រឿងចក្រម៉ាក John Deere៖** ដោយយោងតាមរបាយការណ៍ផ្ទៃក្នុងរបស់ក្រុមហ៊ុន រថយន្តម៉ាក John Deere នៅជាអ្នកនាំមុខទី២ នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធុនធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា។

**លទ្ធផលហិរញ្ញវត្ថុ៖**

ដោយសារតែស្ថានភាពទីផ្សារក្នុងវិស័យយានយន្តនៅកម្ពុជាមិនសូវល្អ, ក្រុមហ៊ុន RMAC ទទួលបានចំណូលចំនួន ៣៦៧ ប៊ីលានរៀល ក្នុងដំណាច់ត្រីមាសទី៣ នៃឆ្នាំ២០២៣ ដែលមានការធ្លាក់ចុះចំនួន -៥៣% ធៀបនឹងដំណាច់ត្រីមាសទី៣ នៃឆ្នាំ២០២២។ សម្រាប់ដំណាច់ត្រីមាសទី៣ នៃឆ្នាំ២០២៣ ប្រាក់ចំណេញក្រោយបង់ពន្ធមានចំនួន ១៣,២ ប៊ីលានរៀល (ធ្លាក់ចុះ-៨៦,៥% បើប្រៀបធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២២)។

លំហូរសាច់ប្រាក់សុទ្ធដែលប្រើប្រាស់លើការវិនិយោគនូវសាច់ប្រាក់មានចំនួន ១៦ ប៊ីលានរៀល ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ដោយរាប់បញ្ចូលការសាងសង់លើបន្ទប់តាំងបង្ហាញថ្មី និងការទិញរថយន្តម៉ាកថ្មីសម្រាប់ប្រតិបត្តិការ និងឧបករណ៍ប្រតិបត្តិការបន្ថែម។

### ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកមួយចំនួនរួមមាន Ford, Land Rover, Changan, After-Sales Mercedes-Benz, Fuso, John Deere, JCB និង Piaggio។ ផលចំណូលរបស់ក្រុមហ៊ុនទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ៖

១. ការលក់ទំនិញ៖ ចំណូលទាក់ទងនឹងការលក់យានយន្ត និងឧបករណ៍ផ្សេងៗ។

២. ចំណូលពីសេវាកម្ម៖ ចំណូលទាក់ទងនឹងសេវាជួសជុល និងថែទាំយានយន្ត និងឧបករណ៍។

តារាងខាងក្រោមបង្ហាញពីចំណូលពីរប្រភេទសម្រាប់ ត្រីមាសទី៣ ឆ្នាំ២០២៣ និងរយៈពេលប្រៀបធៀបកាលពីឆ្នាំមុន។

| គិតជាពាន់រៀល | ត្រីមាសទី៣ ឆ្នាំ២០២៣ | ភាគរយ | ត្រីមាសទី៣ ឆ្នាំ២០២២ | ភាគរយ | ត្រីមាសទី៣ ឆ្នាំ២០២១ | ភាគរយ |
|---|---|---|---|---|---|---|
| **ការលក់ទំនិញ** | ៣៤៦.៣៦៥.៥២៨ | ៩៤,៥% | ៧៧៣.១៤៧.៤៧៦ | ៩៨,៤% | ៤៥៨.០៧២.១៥៤ | ៥៨,៣% |
| **ចំណូលនៃសេវាកម្ម** | ២០.២៩២.១៨២ | ៥,៥% | ១២.៥៤៦.៤១៥ | ១,៦% | ១១.៨៣៨.២៣០ | ១,៥% |
| **សរុប** | ៣៦៦.៦៥៧.៧១០ | ១០០,០% | ៧៨៥.៦៩៣.៨៩១ | ១០០,០% | ៤៦៩.៩១០.៣៨៤ | ១០០,០% |

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ

សូមយោងទៅកាន់ឧបសម្ព័ន្ធស្តីពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នប្រចាំត្រីមាស គិតត្រឹម

ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

## ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ៣៦៦,៧ ប៊ីលានរៀល ធ្លាក់ចុះចំនួន -៤១៩,០ ប៊ីលានរៀល ឬ -៥៣,៣% ភាគរយ នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ បើធៀបនឹងត្រីមាសក្នុង ឆ្នាំ២០២២។

#### ២. ផ្នែកនៃចំណូល

ផ្នែករថយន្ត Ford ត្រូវទទួលបានការប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងនៅក្នុងកំឡុងត្រីមាសនេះ។ ខណៈពេលដែលម៉ាករថយន្តប្រណិតរបស់ RMAC គឺ Land Rover, គ្រឿងចក្រធុនធ្ងន់ (Heavy-Equipment) និងម៉ាកយានយន្តថ្មីរបស់ប្រទេសចិន Changan បានទទួលការកើនឡើងកំណត់ត្រា២ខ្ទង់។

#### ៣. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ត្រីមាសទី៣ ឆ្នាំ២០២៣ | ត្រីមាសទី៣ ឆ្នាំ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ៣៦៦.៦៥៧.៧១០ | ៧៨៥.៦៩៣.៨៩១ | (៤១៩.០៣៦.១៨១) | -៥៣,៣% |
| ចំណេញដុល | ៥៨.៦៤៤.៨៧៧ | ១៥០.៥៦៨.៣៧៥ | (៩១.៩២៣.៤៩៨) | -៦១,១% |
| គម្លាតចំណេញដុល | ១៦,០% | ១៩,២% | | |
| ចំណាយ | ៣៣.៩៣៧.៤៥៩ | ២៥.៥០៥.០៥៩ | ៨.៤៣២.៤០០ | ៣៣,១% |
| ចំណាយហិរញ្ញវត្ថុ | ៨.៧៥២.០៧២ | ៣.៤៧៣.៨៣៤ | ៥.២៧៨.២៣៨ | ១៥១,៩% |
| ប្រាក់ចំណេញមុនបង់ពន្ធ | ១៥.៩៥៥.៣៤៦ | ១២១.៥៨៩.៤៨២ | (១០៥.៦៣៤.១៣៦) | -៨៦,៩% |
| គម្លាត | ៤,៤% | ១៥,៥% | | |

#### ៤. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ត្រីមាសទី៣ ឆ្នាំ២០២៣ | ត្រីមាសទី៣ ឆ្នាំ ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ១៥.៩៥៥.៣៤៦ | ១២១.៥៨៩.៤៨២ | (១០៥.៦៣៤.១៣៦) | -៨៦,៩% |
| ចំណាយពន្ធ | ២.៧១១.៨២៧ | ២៣.១៥២.៥០៣ | (២០.៤៤០.៦៧៦) | -៨៨,៣% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ១៣.២៤៣.៥១៩ | ៩៨.៤៣៦.៩៧៩ | (៨៥.១៩៣.៤៦០) | -៨៦,៥% |
| គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ | ៣.៦% | ១២,៥% | | |

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

ជាទូទៅអតិថិជនរបស់ RMAC នៅក្នុងប្រទេសកម្ពុជាបានបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការទិញផលិតផលសំខាន់ៗរបស់ RMAC ដែលមានដូច ជា Ford, Changan, John Deere និង Land Rover ។

បច្ចុប្បន្ន RMAC កំពុងតាមដានយ៉ាងជិតដល់នូវការនាំចូល និងស្តុកទុកនូវធនធាននៃផលិតផលសម្រាប់ផ្នែកនីមួយៗ ដើម្បីធ្វើការសម្រេចចិត្តសមស្របតាមលក្ខខណ្ឌនៃការបញ្ជាទិញផលិតផល។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។

### ៣. ការវិភាគអំពីពន្ធដារ

មិនមានការប្រែប្រួលលើលិខិតបទដ្ឋានគតិយុត្តិផ្នែកពន្ធដារក្នុងប្រទេសកម្ពុជាណាមួយ ដែលនាំអោយមានផលប៉ះពាល់សំខាន់ណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី២ ឆ្នាំ២០២៣ ប្រៀបធៀបរយៈពេលនេះជាមួយនឹងឆ្នាំ ២០២២ ត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលថ្មីត្រូវបានបោះឆ្នោតជ្រើសរើសនៅខែសីហា ឆ្នាំ២០២៣។ ការផ្លាស់ប្តូរអ្នកដឹកនាំបានបង្ហាញពីភាពរឹងមាំ រួមជាមួយនឹងភាពបត់បែន។ ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលវិញ គឺមិនត្រូវបានរំពឹងថានឹងមានការផ្លាស់ប្តូរក្នុងរយៈពេលដ៏ខ្លីខាងមុខនេះទេ។

## ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ

មិនមានព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសនេះទេ។

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣

បានឯកភាព និង អនុម័ត

ឈ្មោះ Kevin Whitcraft

តួនាទី៖ ប្រធានក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អ អិម អេ (ខេមបូឌា) ម.ក
R M A (CAMBODIA) PLC.
KINGDOM OF CAMBODIA

បានឯកភាព និង អនុម័ត

ឈ្មោះ ងន សាំង

តួនាទី៖ នាយកប្រតិបត្តិ

